**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តឧត្តរមានជ័យ**

សំណុំរឿងរដ្ឋប្បវេណីលេខ: ០៧៩

ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣

សាលក្រមលេខ: ៥៦ (ក)/៩១

ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣

## គោរពនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តឧត្តរមានជ័យ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ និងប្រកាសសាលក្រមនៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០២៣ នៅសាលជម្រះក្តី នៃសាលាដំបូងខេត្តឧត្តរមានជ័យ ។

**សមាសភាពជំនុំជម្រះមានដូចតទៅ៖**

**ចៅក្រមជំនុំជំម្រះ**

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ លើសំណុំរឿងរដ្ឋប្បវេណីលេខ: ០៧៩ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ដែលមានគូវិវាទរវាង៖

**-ដើមចោទឈ្មោះ** [redacted]សម្បត្តិ ភេទស្រី អាយុ ៣២ឆ្នាំ មុខរបរ មន្ត្រីរាជការ មានទីលំនៅបច្ចុប្បន្ន [redacted]

-ចុងចម្លើយឈ្មោះ [redacted]កក្តី ភេទប្រុស អាយុ ៣៨ឆ្នាំ មុខរបរ កងរាជអាវុធហត្ថខេត្តឧត្តរមានជ័យ មានទីលំនៅ [redacted]

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអណត្តិ មានការិយាល័យ [redacted]

**១.អង្គហេតុ និងការអះអាងរបស់គូភាគី**

**១.១. ខ្លឹមសារសាលក្រមដែលដើមចោទទាមទារ**

១.១.ប្តឹងសុំផ្តាច់សមគ្គសង្វាសជាមួយចុងចម្លើយឈ្មោះ [redacted]កក្តី ភេទប្រុស ចាប់ពីពេលនេះតទៅ ។

១.២.សុំសិទ្ធិគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាកូនចំនួន ០២នាក់៖ ឈ្មោះ [redacted]ចាន់វឌ្ឍនាការ ភេទប្រុស (កើតឆ្នាំ២០១៦) និងឈ្មោះ [redacted]សម្បត្តិមន្នីរាជ ភេទប្រុស។

១.៣.ប្តឹងសុំឱ្យចុងចម្លើយបង់អាហារកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូនចំនួន ០២នាក់ ក្នុងម្នាក់ៗ ចំនួន ៣០០.០០០៛ (សាមសិបម៉ឺន) រៀល រហូតដល់នីតិភាព។

១.៤.ចំពោះទ្រព្យសម្បត្តិរួមដែលមាន៖



Scanned with CamScanner

ក.ដីទំហំ ១០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្ម មានទំហំ ៦.៥ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោកគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ប្រគល់ឱ្យចុងចម្លើយជាអ្នកមានសិទ្ធិគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ។

ខ.ដីមានទំហំ ២០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្មជាន់ផ្ទាល់ដី និងឈើលើមានទំហំ ៩ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដើមចោទសុំសិទ្ធិគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ។

១.៥.ប្រគល់រថយន្តម៉ាក ហៃឡេនដឺ ស៊េរីឆ្នាំ២០០២ ពណ៌ប្រាក់ ពាក់ស្លាកលេខ ឧត្តរមានជ័យ ២A-០៥៩៥ ឱ្យទៅចុងចម្លើយជាអ្នកមានសិទ្ធិគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ។

១.៦.ប្តឹងសុំទាមទារប្រាក់ចំនួន ៨.០០០$ (ប្រាំបីពាន់) ដុល្លារអាមេរិក ថ្លៃប្រគល់រថយន្តម៉ាក ហៃឡេនដឺ ស៊េរីឆ្នាំ២០០២ ពណ៌ប្រាក់ ពាក់ស្លាកលេខ ឧត្តរមានជ័យ ២A-០៥៩៥ ឱ្យមកដើមចោទ។

១.៧.ចំពោះប្រាក់ប្រដាប់ក្តីលើកម្មវត្ថុផ្សេងៗ ដើមចោទជាអ្នកទទួលបន្ទុក ។

**១-២-ការពន្យល់ត្រួសៗអំពីរឿងក្តី**

ដើមចោទ និងចុងចម្លើយបានរួមរស់នៅជាមួយជាប្តីប្រពន្ធតាំងពីឆ្នាំ២០១៤ ដោយបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ នៅក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាគូរភាគីបានបង្កើតបានកូនចំនួន ០២នាក់ ឈ្មោះ [redacted]ចាន់វឌ្ឍនាការ ភេទប្រុស កើតឆ្នាំ២០១៦ និងឈ្មោះ [redacted]សម្បត្តិមន្នីរាជ ភេទប្រុស។ មិនតែប៉ុណ្ណោះគូរភាគីបានបង្កើតទ្រព្យសម្បត្តិរួមជាមួយគ្នាដែលមាន អចលនវត្ថុចំនួន ០២ កន្លែង រួមមាន ៖ ដីទំហំ ១០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្ម មានទំហំ ៦.៥ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោកគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ និងដីមានទំហំ ២០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្មជាន់ផ្ទាល់ដី និងឈើលើមានទំហំ ៩ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ លើសពីនេះទៅទៀតគូរភាគីមានរថយន្តចំនួន ០១គ្រឿងទៀត ម៉ាក ហៃឡេនដឺ ស៊េរីឆ្នាំ២០០២ ពណ៌ប្រាក់ ពាក់ស្លាកលេខ ឧត្តរមានជ័យ ២A-០៥៩៥ ដែលជាទ្រព្យសម្បត្តិរួមរបស់អ្នកទាំងពីរក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នា។ ប៉ុន្តែក្រោយមកក្នុងឆ្នាំ២០២០ ដើមចោទ និងចុងចម្លើយមានរឿងរកាំរកុះជាមួយគ្នាជាបន្តបន្ទាប់រហូត និងចុងចម្លើយបានជេរប្រមាថ គំរាមកំហែងថានឹងសម្លាប់មកលើដើមចោទឥតឈប់ឈរ ដែលនេះជាមូលហេតុនាំឱ្យដើមចោទអស់មនោសញ្ចេតនាក្នុងការរួមរស់នៅជាមួយគ្នា ហើយពុំអាចមានសង្ឃឹមថានឹងអាចរួមរស់នៅជាមួយគ្នាទៀតបាន ទើបដើមចោទសម្រេចដាក់ពាក្យបណ្តឹងមកតុលាការ។

**១-៣- សេចក្តីថ្លែងការណ៍របស់គូភាគី**

**ក-សេចក្តីថ្លែងការណ៍របស់ដើមចោទ**

ឈ្មោះ [redacted]សម្បត្តិ បានថ្លែងការណ៍ថា: ខ្លួនសូមរក្សាសេចក្តីថ្លែងការណ៍ដូចក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ និងរក្សាការទាមទារដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ទុកជាបានការដដែល។ ក្នុងនីតិវិធីសវនាការនាពេលនេះខ្លួននៅតែបន្តស្នើសុំលែងលះគ្នាជាមួយចុងចម្លើយឈ្មោះ [redacted] កក្តី ដដែល នឹងស្នើសុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២នាក់ ដែលមានឈ្មោះ [redacted] ចាន់វឌ្ឍនាការ ភេទប្រុស កើតឆ្នាំ ២០១៦ និងឈ្មោះ [redacted] សម្បត្តិមន្នីរាជ ភេទប្រុស និងស្នើសុំអាហារកិច្ចសម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូនក្នុងម្នាក់ៗ ចំនួន ៤០០.០០០៛ (សែសិបម៉ឺន) រៀល រហូតដល់កូនមាននីតិភាព។ ដោយឡែកទ្រព្យសម្បត្តិរួម ខ្លួនស្នើសុំសិទ្ធិគ្រប់គ្រងលើដីមានទំហំ ២០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្មជាន់ផ្ទាល់ដី និងឈើលើមានទំហំ ៩ម៉ែត្រ



Scanned with CamScanner

គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ និងប្រគល់សិទ្ធិគ្រប់គ្រងលើដីទំហំ ១០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្ម មានទំហំ ៦.៥ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោកគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ឱ្យទៅចុងចម្លើយជាមានសិទ្ធិគ្រប់គ្រងថែរក្សា។ ចំពោះឡានចំនួន ០១ គ្រឿង ម៉ាកហៃឡេនដឺ ស៊េរីឆ្នាំ២០០២ ពណ៌ប្រាក់ ពាក់ស្លាកលេខ ឧត្តរមានជ័យ ២A-០៥៩៥ ខ្លួនយល់ព្រមប្រគល់ឱ្យចុងចម្លើយ ប៉ុន្តែខ្លួនស្នើសុំប្រាក់ចំនួន ៨.០០០$ (ប្រាំបីពាន់) ដុល្លារអាមេរិក ជាថ្លៃដែលខ្លួនប្រគល់ឡាននោះឱ្យទៅចុងចម្លើយប្រើប្រាស់ផ្ដាច់។ ចំពោះប្រាក់ប្រដាប់ក្ដី និងការបង់ពន្ធផ្សេងៗ ខ្លួនជាអ្នកទទួលបន្ទុក។ ខ្លួនមិនអាចបន្តរួមរស់នៅជាប្ដីប្រពន្ធជាមួយចុងចម្លើយឈ្មោះ [redacted]ភក្តី បានទៀតនោះទេ។

**<u>ខ-សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ</u>**

ឈ្មោះ [redacted]ភក្តី បានថ្លែងការណ៍ថា: នៅក្នុងនីតិវិធីសវនាការនាពេលនេះ ខ្លួនឯកភាពលែងលះគ្នាជាមួយដើមចោទឈ្មោះ [redacted] សម្បត្តិ នឹងយល់ព្រមប្រគល់សិទ្ធិគ្រប់គ្រងលើកូនចំនួន ០២នាក់ ដែលមានឈ្មោះ [redacted] ចាន់វឌ្ឍនាការ ភេទប្រុស កើតឆ្នាំ២០១៦ និងឈ្មោះ [redacted]សម្បត្តិមន្នីរាជ ភេទប្រុស ឱ្យទៅដើមចោទជាអ្នកគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា និងឯកភាពបង់អាហារកិច្ចសម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូនក្នុងម្នាក់ៗ ចំនួន ៤០០.០០០៛ (សែសិបម៉ឺន) រៀល ក្នុងមួយខែ រហូតដល់កូនមាននីតិភាព។ ប៉ុន្តែខ្លួនស្នើសុំសិទ្ធិគ្រប់គ្រងលើដីមានទំហំ ២០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្មជាន់ផ្ទាល់ដី និងឈើលើមានទំហំ ៩ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ វិញ ដោយខ្លួនយល់ព្រមប្រគល់ដីទំហំ ១០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្ម មានទំហំ ៦.៥ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោកគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ឱ្យទៅដើមចោទ។ ដោយឡែកចំពោះឡានចំនួន ០១ គ្រឿង ម៉ាកហៃឡេនដឺ ស៊េរីឆ្នាំ២០០២ ពណ៌ប្រាក់ ពាក់ស្លាកលេខ ឧត្តរមានជ័យ ២A-០៥៩៥ ខ្លួនឯកភាពទទួលយកតាមការស្នើសុំរបស់ដើមចោទ ប៉ុន្តែខ្លួនសូមបដិសេធការទាមទារប្រាក់ចំនួន ៨.០០០$ (ប្រាំបីពាន់) ដុល្លារអាមេរិក ជាថ្លៃដែលដើមចោទព្រមប្រគល់ឡានឱ្យមកខ្លួននោះ ខ្លួនស្នើសុំតុលាការច្រានចោលការទាមទារនេះ។

**<u>សំអាងហេតុ</u>**

១.ទទួលស្គាល់ពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ [redacted]សម្បត្តិ ភេទស្រី អាយុ ៣២ឆ្នាំ សញ្ជាតិខ្មែរ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២៣ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ផ្អែកតាមមាត្រា ៧៤ និងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

២.ការរៀបអាពាហ៍ពិពាហ៍របស់គូរភាគីទាំងពីរគឺ មិនបានបំពេញលក្ខខណ្ឌគតិយុត្តឡើយ ក្រោយពេលរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណី ដើមចោទ និងចុងចម្លើយ ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាទេ ពោលគឺដើមចោទ និងចុងចម្លើយ កន្លងមករួមរស់នៅជាមួយគ្នាបែបអនីតិសង្វាសតែប៉ុណ្ណោះ។

៣.ការរួមរស់នៅជាមួយគ្នារបស់ដើមចោទ និងចុងចម្លើយគឺ មានកូនចំនួន ០២នាក់ ដែលមានឈ្មោះ [redacted] ចាន់វឌ្ឍនាការ ភេទប្រុស កើតឆ្នាំ២០១៦ និងឈ្មោះ [redacted] សម្បត្តិមន្នីរាជ ភេទប្រុស និងទ្រព្យសម្បត្តិរួមមានដូចជាអចលនវត្ថុចំនួន ០២ កន្លែង រួមមាន៖ ដីទំហំ ១០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្ម មានទំហំ ៦.៥ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោកគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ និងដីមានទំហំ ២០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្មជាន់ផ្ទាល់ដី និងឈើលើមានទំហំ ៩ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ លើសពីនេះទៅទៀតគូរភាគីមានបំណុល



Scanned with CamScanner

ចំនួន ០១គ្រឿងទៀត ម៉ាកហៃឡេនដឺ ស៊េរីឆ្នាំ២០០២ ពណ៌ប្រាក់ ពាក់ស្លាកលេខ ឧត្តរមានជ័យ ២A-០៥៩៥ ដែលជាទ្រព្យសម្បត្តិរួម។

៤.ផ្អែកតាមសេចក្តីថ្លែងការណ៍របស់គូរភាគីក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា ដើមចោទ និងចុងចម្លើយ ឯកភាពគ្នាលើការលែងលះគ្នា។ ប៉ុន្តែតុលាការពិនិត្យឃើញថា ការរួមរស់នៅជាមួយគ្នារបស់គូរភាគី មិនបានបំពេញលក្ខខណ្ឌគតិយុត្តតាមច្បាប់ដែលតម្រូវឡើយ ដែលធ្វើឱ្យការរួមរស់នៅជាមួយគ្នាគ្រាន់តែជាការរួមរស់នៅបែបអនីតិសង្វាសតែប៉ុណ្ណោះ គប្បីតុលាការពិនិត្យពិចារណាតាមនីតិវិធីច្បាប់។

៥.ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ចុងចម្លើយឃើញថា ចុងចម្លើយឯកភាពប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន ០២នាក់ ដែលមានឈ្មោះ[redacted]ចាន់វឌ្ឍនាការ ភេទប្រុស កើតឆ្នាំ២០១៦ និងឈ្មោះ[redacted]សម្បត្តិមន្នីរាជ ភេទប្រុស ឱ្យទៅដើមចោទ ជាអ្នកចិញ្ចឹមបីបាច់ថែរក្សា។ ដូច្នេះផ្អែកតាមមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បើឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ។ គប្បីតុលាការពិនិត្យពិចារណា និងសម្រេចប្រគល់សិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ខាងលើឱ្យទៅដើមចោទឈ្មោះ[redacted] សម្បត្តិ តាមការព្រមព្រៀងរបស់គូរភាគី។

៦.ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ បានស្នើសុំឱ្យចុងចម្លើយផ្តល់អាហារកិច្ចសម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូនទាំងពីរនាក់ចំនួន ៨០០.០០០៛ (ប៉ែតសិបម៉ឺន) រៀល ក្នុងមួយខែ រហូតដល់កូនមាននីតិភាព ដែលការស្នើសុំនេះឃើញថា ចុងចម្លើយបានឯកភាពលើការស្នើសុំរបស់ដើមចោទនេះ។ ផ្អែកតាមមាត្រា ១០៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឃើញថា ឪពុក ឬម្តាយ ដែលពុំមានអំណាចមេបាលើកូន ក្រោយពេលលែងលះគ្នាមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ដែលចំណុចនេះឃើញថា គូរភាគីបានឯកភាពគ្នាដោយចុងចម្លើយបានយល់ព្រមបង់សោហ៊ុយចាំបាច់ដើម្បីថែក្សាកូនចំនួន ៨០០.០០០៛ (ប៉ែតសិបម៉ឺន) រៀល ក្នុងមួយខែ រហូតដល់កូនមាននីតិភាព តាមការស្នើសុំរបស់ដើមចោទ។ គប្បីតុលាការពិនិត្យពិចារណា និងសម្រេចបង្គាប់ឱ្យចុងចម្លើយបង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូនទាំងពីរនាក់ឱ្យដើមចោទ រហូតដល់កូនមាននីតិភាព តាមការព្រមព្រៀងរបស់គូរភាគី។

៧.ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ និងចុងចម្លើយឃើញថា ដើមចោទ និងចុងចម្លើយ មិនឯកភាពគ្នាលើការបែងចែកទ្រព្យសម្បត្តិរួម ដែលមាន៖ ដីទំហំ ១០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្ម មានទំហំ ៦.៥ ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោកគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ និងដីមានទំហំ ២០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្មជាន់ផ្ទាល់ដី និងឈើលើមានទំហំ ៩ម៉ែត្រ គុណនឹង ១២ ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ឡើយ។ ជារួមតុលាការយល់ឃើញថា ក្នុងអង្គហេតុនេះដើមចោទ និងចុងចម្លើយ ពុំឯកភាពគ្នាលើការបែងចែកទ្រព្យសម្បត្តិឡើយ ដូច្នេះផ្អែកតាមមាត្រា ៩៧៣ និងមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការពិនិត្យពិចារណាដោយធ្វើការបែងចែកទ្រព្យសម្បត្តិរួមនេះតាមច្បាប់កំណត់ ដោយយុត្តិធម៌ជូនគូរភាគី។

៨.នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការពិនិត្យឃើញថា ដើមចោទបានឯកភាពប្រគល់សិទ្ធិគ្រប់គ្រងលើរថយន្តចំនួន ០១គ្រឿង ម៉ាកហៃឡេនដឺ ស៊េរីឆ្នាំ២០០២ ពណ៌ប្រាក់ ពាក់ស្លាកលេខ ឧត្តរមានជ័យ ២A-០៥៩៥ ដែលជាទ្រព្យសម្បត្តិរួម ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រងថែរក្សា ហើយចុងចម្លើយក៏បានឯកភាពគ្នាទទួលយករថយន្តខាងលើមកគ្រប់គ្រងថែរក្សាផងដែរ។ តាមរយៈការបញ្ជាក់នេះសបង្ហាញឱ្យឃើញថា គូរភាគីឯកភាពគ្នាលើការបែងចែករថយន្តដែលជាទ្រព្យសម្បត្តិរួមនេះរួចរាល់ហើយ ផ្អែកតាមមាត្រា ៩៧៣ និងមាត្រា ៩៨០ កថាខណ្ឌទី០១ នៃក្រមរដ្ឋប្បវេណី ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យ



Scanned with
CamScanner

សម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង។ គប្បីតុលាការពិនិត្យពិចារណា និងសម្រេចប្រគល់សិទ្ធិគ្រប់គ្រងរថយន្តចំនួន ០១គ្រឿង ម៉ាកហៃឡេនជី សេរីឆ្នាំ២០០២ ពណ៌ប្រាក់ ពាក់ស្លាកលេខ ឧត្តរមានជ័យ ២A-០៥៩៥ ឱ្យទៅចុងចម្លើយឈ្មោះ[redacted]ភក្តី ជាអ្នកគ្រប់គ្រងថែរក្សា តាមការព្រមព្រៀងរបស់គូរភាគី។

៩.ក្នុងពេលនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទស្នើសុំទាមទារប្រាក់ចំនួន ៨.០០០$ (ប្រាំបីពាន់) ដុល្លារអាមេរិក ជាថ្លៃដែលដើមចោទព្រមប្រគល់ឡានឱ្យមកចុងចម្លើយ តុលាការយល់ឃើញថា ការទាមទារគឺផ្ទុយពីធន្ទះដែលដើមចោទខ្លួនឯងប្រគល់ឡានឱ្យទៅចុងចម្លើយ ហើយបែរជាសុំទាមទារប្រាក់ពីការប្រគល់ឡាននោះពីចុងចម្លើយទៅវិញ ដែលការទាមទារនេះមិនមានមូលហេតុសមស្របដែលតម្រូវឱ្យតុលាការលើកមកពិចារណាឡើយ។ គប្បីតុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុចដែលដើមចោទទាមទារប្រាក់ចំនួន ៨.០០០$ (ប្រាំបីពាន់) ដុល្លារអាមេរិក ជាថ្លៃដែលដើមចោទព្រមប្រគល់ឡានឱ្យមកចុងចម្លើយ ចោលទាំងស្រុង។

១០.ផ្អែកតាមពាក្យបណ្តឹងចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ឃើញថា ដើមចោទបានស្នើសុំទទួលបន្ទុកប្រាក់ប្រដាប់ក្តីទាំងអស់ យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីតុលាការសម្រេចបង្គាប់ឱ្យដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តីទាំងអស់ តាមការស្នើសុំរបស់ដើមចោទ។

## <u>៣- សេចក្តីសម្រេចបញ្ចប់</u>

១. ទទួលស្គាល់ពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ[redacted]**សម្បត្តិ** ភេទស្រី អាយុ ៣២ឆ្នាំ សញ្ជាតិខ្មែរ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២៣ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២. បញ្ឈប់ការរស់នៅបែបអនីតិសង្វាសរវាងដើមចោទឈ្មោះ [redacted]**សម្បត្តិ** និងចុងចម្លើយឈ្មោះ[redacted]**ភក្តី** ចាប់ពីពេលនេះតទៅ ។

៣. ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន ០២នាក់ ដែលមាន៖ ឈ្មោះ [redacted]ចាន់វឌ្ឍនាការ ភេទប្រុស កើតឆ្នាំ២០១៦ និងឈ្មោះ[redacted] សម្បត្តិមន្នីរាជ ភេទប្រុស ឱ្យទៅដើមចោទឈ្មោះ[redacted]**សម្បត្តិ** ជាអ្នកគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា ទុកសិទ្ធិឱ្យចុងចម្លើយឈ្មោះ[redacted]**ភក្តី** អាចមកសួរសុខទុក្ខកូនបានរៀងរាល់ថ្ងៃសៅរ៍-អាទិត្យ វេលាម៉ោង ០៩ព្រឹកដល់ម៉ោង ០៥ល្ងាច។ មាតាបិតាត្រូវមានសិទ្ធិ និងករណីកិច្ចអប់រំចិញ្ចឹមបីបាច់ថែរក្សាកូនឱ្យបានល្អតាមបញ្ញត្តិច្បាប់ ។

៤.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] **ភក្តី** ទទួលបន្ទុកសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនចំនួន ៨០០.០០០៛ (ប៉ែតសិបម៉ឺន) រៀល ក្នុងមួយខែ រហូតដល់កូនទាំងពីរនាក់ដល់នីតិភាព។

**៥.ការបែងចែកទ្រព្យសម្បត្តិរួម៖**

៥.១.ប្រគល់សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួមចំនួន ០១កន្លែង ដែលមាន៖ ដីទំហំ ១០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្ម មានទំហំ ៦.៥ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោកគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ឱ្យទៅដើមចោទឈ្មោះ[redacted]**សម្បត្តិ** ជាអ្នកគ្រប់គ្រងថែរក្សា។

៥.២.ប្រគល់សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួមចំនួន ០១កន្លែង ដែលមាន៖ ដីមានទំហំ ២០ម៉ែត្រ គុណនឹង ៦០ ម៉ែត្រ និងផ្ទះប្រភេទផ្ទះថ្មជាន់ផ្ទាល់ដី និងឈើលើមានទំហំ ៩ម៉ែត្រ គុណនឹង ១២ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិគោកគរ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ឲ្យទៅចុងចម្លើយឈ្មោះ[redacted]**ភក្តី** ជាអ្នកគ្រប់គ្រងថែរក្សា។



Scanned with CamScanner

៥.៣.ប្រគល់សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួមដែលមាន៖ រថយន្តចំនួន ០១ គ្រឿង ម៉ាកហៃឡេនឌឺ ស៊េរីឆ្នាំ២០០២ ពណ៌ប្រាក់ ពាក់ស្លាកលេខ ឧត្តរមានជ័យ ២A-០៥៩៥ ឱ្យទៅចុងចម្លើយឈ្មោះ [redacted] **ភក្តី** ជាអ្នកគ្រប់គ្រងថែរក្សាតាមការព្រមព្រៀងរបស់គូភាគី។

៦.ច្រានចោលការទាមទារចំណុចទី ០៦ របស់ដើមចោទឈ្មោះ [redacted] **សម្បត្តិ** ក្នុងពាក្យបណ្តឹងចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ចោលទាំងស្រុង។

៧.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ ចំពោះមុខដើមចោទឈ្មោះ [redacted] **សម្បត្តិ** និងចុងចម្លើយឈ្មោះ [redacted] **ភក្តី**។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ខេត្តឧត្តរមានជ័យ, ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣
**ចៅក្រម**
**ហត្ថលេខា និងត្រា** [redacted]

**បានឃើញ**
ថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ខេត្តឧត្តរមានជ័យ,ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣
**ចៅក្រម**
[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ខេត្តឧត្តរមានជ័យ,ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner